4-8-23
F1774

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**
លេខ...០៣៧.........អ.ស.ហ..ប្រ.ក

# ប្រកាស
## ស្តីពី
## បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- យោងតាមការចំបាច់របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីក្របខណ្ឌគ្រប់គ្រងការអនុវត្តបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុរបស់និយ័តករពាក់ព័ន្ធក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ក្នុងគោលដៅជំរុញការចាប់យក ការសម្រប និងការធ្វើនវានុវត្តន៍បច្ចេកវិទ្យានៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ស្របតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥។

**ប្រការ២.-**

បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ សំដៅដល់បរិស្ថានសម្រាប់ឱ្យក្រុមហ៊ុនពាក់ព័ន្ធនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ សាកល្បងនូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុរបស់ខ្លួនជាមួយនឹងអតិថិជនពិតប្រាកដ ប៉ុន្តែក្នុងទំហំនិងរយៈពេលកំណត់មួយ មុននឹងធ្វើការដាក់ចេញ និងការជំរុញការប្រើប្រាស់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុនោះឱ្យបានទូលំទូលាយ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ៣.-**

និយ័តករពាក់ព័ន្ធក្រោមឱវាទ **អ.ស.ហ.** ត្រូវដាក់ចេញនូវគោលការណ៍ណែនាំស្តីពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលកំណត់អំពីគោលដៅ គោលការណ៍ លក្ខខណ្ឌវិនិច្ឆ័យ នីតិវិធីនៃការដាក់ពាក្យស្នើសុំ លក្ខខណ្ឌតម្រូវសម្រាប់ការអនុញ្ញាតចូលរួមក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ កាតព្វកិច្ចក្នុងដំណាក់កាលសាកល្បង កាតព្វកិច្ចបន្ទាប់ពីដំណាក់កាលសាកល្បង និងព័ត៌មានដែលត្រូវផ្តល់ជូននិយ័តករ សំដៅធានាបាននូវការគ្រប់គ្រង និងការត្រួតពិនិត្យលើការសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុពាក់ព័ន្ធនឹងផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលស្ថិតក្រោម ឬអាចនឹងស្ថិតក្រោមនិយ័តកម្មរបស់និយ័តករពាក់ព័ន្ធក្រោមឱវាទ **អ.ស.ហ.**។

**ប្រការ៤.-**

បុគ្គលដែលមានបំណងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុតាមបែបនវានុវត្តន៍ក្នុងការផ្តល់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលស្ថិតក្រោម ឬអាចនឹងស្ថិតក្រោមនិយ័តកម្មរបស់និយ័តករពាក់ព័ន្ធក្រោមឱវាទ **អ.ស.ហ.** ត្រូវដាក់ពាក្យស្នើសុំ និងទទួលបានការអនុញ្ញាតជាមុន ដើម្បីចូលរួមក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ ស្របតាមគោលការណ៍ណែនាំស្តីពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុរបស់និយ័តករពាក់ព័ន្ធក្រោមឱវាទ **អ.ស.ហ.**។

បុគ្គលដែលមានបំណងចូលរួមក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ ត្រូវជាក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការស្នើសុំការអនុញ្ញាតគឺត្រូវធ្វើឡើងស្របតាមទម្រង់បែបបទ និងត្រូវភ្ជាប់មកជាមួយនូវឯកសារភ្ជាប់ដែលកំណត់ដោយនិយ័តករពាក់ព័ន្ធក្រោមឱវាទ **អ.ស.ហ.**។

និយ័តករពាក់ព័ន្ធក្រោមឱវាទ **អ.ស.ហ.** អាចដាក់ចេញ និងតម្រូវឱ្យអនុវត្តនូវសៀវភៅបន្ទុកសម្រាប់គ្រប់គ្រងការសាកល្បងរបស់ក្រុមហ៊ុនពាក់ព័ន្ធនីមួយៗ ក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** អគ្គនាយកនៃនិយ័តករពាក់ព័ន្ធ ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** និងអង្គភាពចំណុះឱ្យ **អ.ស.ហ.** ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៣ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែសីហា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី
- ឯកឧត្ដមនិងលោកជំទាវអនុប្រធាន និងសមាជិកក្រុមប្រឹក្សា-អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៦
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ